# ព្រែកទឹកសាប　　**A1 & A4i**



**ខេត្ត** : ក្រុងព្រះសីហនុ

**ស្រុក** : ព្រៃនប់

**ផ្ទៃដី ( ហិកតា)** : ៣.៥៧៩

**រយៈកំពស់ ( ម៉ែត្រ)** : 0 ដល់ ១១១

**កូអរដោនេចំណុចកណ្តាល** : ១០$^{0}$៣៤' ជ　១០៣$^{0}$៤១' ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានមាត់ពាមនៃព្រែកទឹកសាបដែលហូរធ្លាក់ចូលទៅក្នុងឈូងសមុទ្រនៃប្រទេសថៃឆ្ពោះទៅទិសខាងកើតនៃឧទ្យានជាតិរាម ។ នៅត្រង់ចំណុចមាត់ពាមមានកោះមួយយ៉ាងធំដែលគេហៅថាកោះថ្មី ។ រុក្ខជាតិនៅក្នុងតំបន់ IBA នេះគ្របដណ្តប់ដោយព្រៃកោងកាង ដែលមួយចំនួនដុះឈរត្រង់ដូចជាប្រភេទ *Nypa* និង មានវាលភក់ដែលទទួលទឹកជោរនាច ព្រមទាំងបណ្តាតំបន់ដែលមានព្រៃស្មាច់រិចរិលនៅប៉ែកខាងលើនៃព្រៃកោងកាង ។ តំបន់ IBA នេះ គឺជាកន្លែងរកស៊ីរបស់ពពួកសត្វស្លាបទឹកមួយចំនួន រួមមានត្រដក់តូច រនាលពណិ ទុងប្រផេះ ។ សំខាន់ជាងនេះទៅទៀតនោះ គឺជាតំបន់រកចំណីនៅក្នុងប្រទេសកម្ពុជារបស់រនាលស ដែលប្រភេទនេះពងកូននៅតំបន់ IBA ព្រែកទាល់ ហើយទំនងជាមិនទាន់បានរកឃើញកន្លែងពងកូនរបស់ប្រភេទនេះនៅឡើយទេនៅប៉ែកនិរតី តែអាចមាននៅក្បែរ ឬ នៅក្នុងតំបន់ IBA នេះតែម្តង ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 |
| រនាលពណិ | Painted Stork | *Mycteria leucocephala* | A1 |
| រនាល ស | Milky Stork | *Mycteria cinerea* | A1 |

## ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក

ស្វាក្តាម ។

## ការគំរាមកំហែងលើជីវៈចំរុះ

ការគំរាមកំហែងចំបងក្នុងតំបន់ IBA នេះ គឺជាការបាត់បង់ទីជំរក ជាពិសេសការរានដីព្រៃកោងកាង ។ ជាងនេះទៅទៀតការបរបាញ់សត្វព្រៃ គឺជាបញ្ហាមួយធ្ងន់ធ្ងរដែលកើតមានឡើងនៅក្នុងតំបន់ឧទ្យានជាតិរាមដែលស្ថិតនៅក្បែរតំបន់នេះ ។

## អនុសាសន៍

បង្កើនការល្បាតនៅតាមបណ្តោយព្រែកទឹកសាបក្នុងឧទ្យានជាតិរាម ដើម្បីត្រួតពិនិត្យការកាប់ព្រៃឈើខុសច្បាប់ និង ការរានដីព្រៃកោងកាង ។

## ឯកសារយោង

Edwards, P. J. (1996) *Cambodia wetlands ornithological survey*. Newmarket: Xenus Ecology.
Goes, F. ed. (1999) Recent sightings. *Cambodia Bird News* 1: 20-23.
Goes, F. ed. (1999) Recent sightings. *Cambodia Bird News* 3: 39-43.
Goes, F. Tan Setha and Ros Bansok (1998) *Preliminary bird survey for cluster of three national parks in southern C ambodia*. Phnom Penh: European Commission Support Programme to the Environment Sector in C ambodia.
Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-Apri l 1994*. Cambridge, UK: IUCN/SSC.